អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង ០០៤

វិធាន ៥៤ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក តម្រូវថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ត្រូវតែសម្ងាត់ ប៉ុន្តែក៏ចែងផងដែរថា សហព្រះរាជអាជ្ញាអាច "ផ្តល់ជូនសាធារណជននូវសេចក្តីសង្ខេប អំពីគោលបំណងនៃព័ត៌មានដែលមានចែងនៅក្នុងដីកាសន្និដ្ឋានទាំងនោះបាន"។ ទន្ទឹមនេះ ដោយមានការយកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់ជនរងគ្រោះនិងសាក្សី សិទ្ធិរបស់ជនសង្ស័យដែលមានសិទ្ធិទទួលបានសច្ចៈធារណ៍នៃនិរទោស និងលក្ខខណ្ឌតម្រូវក្នុងវិធាននានាដែលកំណត់ថាកិច្ចស៊ើបសួរត្រូវតែធ្វើឡើងដោយសម្ងាត់ សហព្រះរាជអាជ្ញាអន្តរជាតិសូមផ្តល់នូវព័ត៌មានដូចខាងក្រោម។

ថ្ងៃនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង០០៤ ដោយស្នើឲ្យមានកិច្ចស៊ើបសួរទៅលើអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅតាមបណ្តាស្រុកសំខាន់ៗមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ ដែលជាផ្នែកនៃសំណុំរឿងនេះ។ បទចោទប្រកាន់ក្នុងនោះរួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ ដែលរួមបញ្ចូលទាំងឧទាហរណ៍ អំពើរំលោភសេពសន្ថវៈជាក្រុមរហូតដល់៨០គូ ដែលបានធ្វើឡើងតាមរយៈអាពាហ៍ពិពាហ៍តែមួយ។ ការចោទប្រកាន់ក៏មានបញ្ចូលផងដែរនូវអំពើរំលោភសេពសន្ថវៈនៅមុនពេលសម្លាប់ និងអំពើហិង្សាខាងផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ រួមទាំងជាតួយ៉ាង ស្ត្រីត្រូវបានគេរំលោភមុនសម្លាប់ និងតួយ៉ាងផ្សេងទៀតដែលស្ត្រី ដែលបានរាយការណ៍អំពីអំពើរំលោភសេពសន្ថវៈទាំងនេះនៅក្នុងសម័យខ្មែរក្រហម ត្រូវបានគេសម្លាប់ចោលជាបន្តបន្ទាប់។ ព័ត៌មានបឋមដែលយើងមាននាពេលនេះបញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាខាងផ្លូវភេទ ដូចបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលខ្មែរក្រហម និងបានកើតឡើងនៅក្នុងតំបន់នានាដែលជនសង្ស័យដែលគេបានស្គាល់ឈ្មោះនៅក្នុងសំណុំរឿង ០០៤ គឺជាអ្នកកាន់មុខនាទីជាអ្នកបញ្ជា ឬនយោបាយដ៏មានឥទ្ធិពល។ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ហើយថ្ងៃនេះក៏សូមស្នើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត បន្តស៊ើបសួរទៅលើឧក្រិដ្ឋកម្មទាំងអស់នេះបន្ថែមទៀតនិងអំពីការទាក់ទងណាមួយទៅនឹងជនសង្ស័យ ដូចដែលមានឈ្មោះទាំងនោះ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ មានមូលដ្ឋាននៅលើភស្តុតាងថ្មីដែលបានក្លាយទៅជាឯកសារដែលអាចរកបានចាប់តាំងពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង០០៤មក។ ភស្តុតាងថ្មីនេះមាននៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះជាច្រើន នៅក្នុងសំណុំរឿង០០២ និងនៅក្នុងចម្លើយភស្តុតាង ដែលកំពុងតែប្រមូលបានជាបន្តបន្ទាប់ពីជនរងគ្រោះដោយផ្អែកលើមូលដ្ឋាននៃសំណុំរឿង០០៤ ដែលកំពុងតែដំណើរការ។ សហព្រះរាជអាជ្ញាអន្តរជាតិ បន្ទាប់ពីបានធ្វើការវិភាគដោយយកចិត្តទុកដាក់លើព័ត៌មាននៅក្នុងអំឡុងពេលប៉ុន្មានខែកន្លងមកនេះ ជឿជាក់ថា ការលើកឡើងនៃចោទប្រកាន់លើអង្គហេតុទាំងឡាយ ដែលមាននៅក្នុងភស្តុតាងថ្មីនេះ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលរួមមាន៖ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត។ អំពើទាំងនេះក៏បង្កើតបានជា អំពើមនុស្សឃាត និង អំពើទារុណកម្ម ដែលជាការរំលោភទៅលើក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ផងដែរ។

សហព្រះរាជអាជ្ញាអន្តរជាតិ ក៏សូមរំលឹកផងដែរដល់សាធារណៈជនថា ជនសង្ស័យគ្រប់រូបទាំងអស់មានសិទ្ធិត្រូវបានសន្មត់ថាមិនទាន់មានទោសនៅឡើយរហូតទាល់តែតុលាការរកឃើញថាមានទោស (សច្ចធារណ៍នីរទោស) និងថា សំណុំរឿងលេខ០០៤ កំពុងតែស្ថិតនៅក្នុងកិច្ចស៊ើបសួរនៅឡើយ។ ភស្តុតាងថ្មីៗនឹងបន្តលេចចេញមក ហើយដូចគ្នាទៅនឹងកិច្ចស៊ើបសួរនឹងការស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌណាមួយផ្សេងទៀតដែរ ជាសំខាន់គឺត្រូវជៀសវាងការធ្វើសេចក្តីសន្និដ្ឋាន រហូតទាល់តែកិច្ចស៊ើបសួរត្រូវបានចប់សព្វគ្រប់សិន ហើយជនសង្ស័យតាមរយៈមេធាវីការពារក្តីរបស់ខ្លួន ត្រូវបានផ្តល់ជូននូវសិទ្ធិដើម្បីធ្វើការស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។

សហព្រះរាជអាជ្ញាអន្តរជាតិ ក៏ទទួលស្គាល់ផងដែរថា យុត្តិធម៌ត្រូវតែធ្វើឲ្យបាន ទាំងឆាប់រហ័ស និងទាំងមានប្រសិទ្ធភាពផង ហើយជនរងគ្រោះទាំងឡាយដោយសារពីឧក្រិដ្ឋកម្មទាំងនេះ បានរង់ចាំយុត្តិធម៌ ជាង៣៥ឆ្នាំ មកហើយ។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ នឹងបន្តគាំទ្រថា ការស៊ើបសួរ និងការចោទប្រកាន់ណាមួយដែលជាលទ្ធផលលេចចេញពីការស៊ើបសួរនេះ ត្រូវផ្តោតទៅលើឧក្រិដ្ឋកម្មទាំងឡាយដែលទាក់ទងដោយផ្ទាល់បំផុតទៅនឹងជនសង្ស័យ/ជនត្រូវចោទ។ ដើម្បីពន្លឿន និងបញ្ចប់ដំណើរការយុត្តិធម៌នៅ អ.វ.ត.ក ឥឡូវនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំឲ្យធ្វើការកែប្រែលើវិធានផ្ទៃក្នុង ដែលឥឡូវនេះកំពុងតែពិចារណាដើម្បីអនុញ្ញាតឲ្យមានការ កាត់បន្ថយទីតាំងឧក្រិដ្ឋកម្មមួយចំនួនដែលស្ថិតនៅក្រោមការស៊ើបសួរ ដែលប្រការនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ជឿជាក់ថា នឹងមានការកាត់បន្ថយនូវពេលវេលាដ៏ច្រើនដែលត្រូវការចាំបាច់ដើម្បីបញ្ចប់កិច្ចស៊ើបសួរលើសំណុំរឿង ០០៤។

ចុងបញ្ចប់នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ទទួលស្គាល់នូវសេចក្តីក្លាហានរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះទាំងឡាយដែលបានមកផ្តល់ភស្តុតាងដ៏សំខាន់នេះជូនដល់មន្ត្រីអ្នកស៊ើបអង្កេតនានានៃអ.វ.ត.ក។ នៅក្នុងយុទ្ធនាការស្តីពីជម្លោះប្រដាប់អាវុធ និងអំពើឃោរឃៅនៅក្នុងពិភពលោកនេះ វាគឺជាបាតុភូតមួយដែលកើតឡើងសារជាថ្មីឡើងវិញ ដោយគេមិនបានរាយការណ៍ឲ្យបានទូលំទូលាយនោះទេ។ ជនរងគ្រោះគ្រប់រូបទាំងអស់ដោយសារអំពើហិង្សាបែបនេះ បានទទួលរងនូវស្នាមរបួសខាងផ្លូវចិត្ត ហើយជាញឹកញាប់គឺខាងផ្លូវកាយដោយសារតែឧក្រិដ្ឋកម្មទាំងនេះ អស់មួយជីវិត។ អាស្រ័យហេតុនេះ យើងក៏ទទួលស្គាល់ផងដែរថា គឺជាករណីយកិច្ចដ៏ឧឡារិករបស់យើងដែលត្រូវធ្វើនូវអ្វីទាំងអស់ដែលយើងអាចធ្វើទៅបាន ដើម្បីធានាសន្តិសុខផ្លូវកាយ ហើយកង្វល់ឯកជនរបស់ជនរងគ្រោះទាំងនេះត្រូវបានគេគោរព ហើយនិង ការពិតអំពីការឈឺចាប់របស់ពួកគេទាំងនេះត្រូវបានគេទទួលស្គាល់៕

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh